# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងសាធារណការ និងដឹកជញ្ជូន

### គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យ
### យានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់

### គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍

# ខិតប័ណ្ណផ្សព្វផ្សាយ អំពីច្បាប់ និងបទប្បញ្ញត្តិនានា ពាក់ព័ន្ធនឹងការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់

រៀបរៀងដោយ លោក ជឹម មករា
សមាជិកលេខាធិការដ្ឋាន គ.ស.អ



## ទស្សនៈវិស័យ

បច្ចុប្បន្ន ក្រោមការដឹកនាំដ៏ឈ្លាសវៃ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ ហេដ្ឋារចនាសម្ព័ន្ធទាំងឡាយ មានការរីកចម្រើនយ៉ាងច្រើន ក្នុងនោះក៏មានវិស័យគមនាគមន៍ផងដែរ ។ ទន្ទឹមនឹងការរីកចម្រើននេះ មូលហេតុចម្បងដែលបណ្តាលឲ្យមានការខូចខាតទៅវិញលើវិស័យផ្លូវថ្នល់ មកពីការដឹកជញ្ជូនលើសទម្ងន់ដែលធ្វើឲ្យខាតបង់ក្នុងការចំណាយថវិកាជាតិទៅលើការថែទាំ និងជួសជុលផ្លូវថ្នល់ទាំងនោះយ៉ាងច្រើន ។

មើលឃើញការខាតបង់ ដូចនេះ ទើបក្រសួងសាធារណការនិងដឹកជញ្ជូន បន្តខិតខំពង្រឹង និងជំរុញប្រតិបត្តិការត្រួតពិនិត្យយានយន្តដឹកលើសទម្ងន់ តាមមធ្យោបាយផ្សេងៗ មានទាំងការផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិ ក៏ដូចជាការចាប់ឃាត់រថយន្តល្មើស ធ្វើការពិន័យតាមច្បាប់ផងដែរ ។

## បេសកកម្ម

ជម្រុញការអនុវត្តន៍ច្បាប់ស្តីពីផ្លូវថ្នល់ពាក់ព័ន្ធនឹងការដឹកជញ្ជូនលើសទម្ងន់ និង ដើម្បីកាត់បន្ថយនូវការខូចខាតផ្លូវថ្នល់ រួមចំណែកក្នុងការសន្សំសំចៃថវិកាជាតិ ព្រមទាំងធ្វើឲ្យប្រសើរឡើងដល់សុវត្ថិភាពហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្លូវគោក ហើយក៏ជួយធានាឲ្យការប្រកួតប្រជែងដោយយុត្តិធម៌ក្នុងការដឹកជញ្ជូន និងការពារបរិស្ថានផងដែរ ។



ការអនុវត្តន៍ការត្រួតពិនិត្យទម្ងន់ផ្ទុករបស់យានយន្តផ្អែកលើមូលដ្ឋានគតិយុត្តិមួយចំនួនដូចខាងក្រោម ៖

- ព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៤ លើច្បាប់ស្តីពីផ្លូវថ្នល់ (ពិសេស មាត្រា២៦ និង មាត្រា៦០)
- ប្រកាសលេខ ៩១១ ប្រក.សក/គតលទ ចុះថ្ងៃទី០២ ខែ កញ្ញា ឆ្នាំ ២០០៩ ស្តីពីការកម្រិតកំណត់ទម្ងន់អតិបរមា របស់យានយន្ត ដែលធ្វើចរាចរលើបណ្តាញផ្លូវជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

## ការកម្រិតកំណត់ទម្ងន់ដឹកជញ្ជូនអតិបរមា តាម មាត្រា ២៦ នៃច្បាប់ស្តីពីផ្លូវថ្នល់

### ១- ការកម្រិតទម្ងន់អតិបរមាសង្កត់លើក្តៀររថយន្ត រ៉ឺម៉ក ឬសឺមីរ៉ឺម៉ក ៖

- ០៦តោន 

- ១០តោន 

- ១១តោន 

- ១៩តោន 

- ២៤តោន 

## ២- ការកម្រិតទម្ងន់សរុបអតិបរមារបស់រថយន្តទោល ៖

- ១៦តោន 

- ២១តោន 

- ២៥តោន 

- ៣០តោន 

- ៣៥តោន 

## ៣- ការកម្រិតទម្ងន់សរុបអតិបរមារថយន្តសណ្តោងរ៉ឺម៉ក ឬសឺមីរ៉ឺម៉ក ៖

- ៣៥តោន 

- ៤០តោន 



- ៣៥តោន 

- ៤០តោន 

*ចំពោះយានយន្ត និងរថយន្តសណ្តោងរ៉ឺម៉ក ឬ សឺមីរ៉ឺម៉ក ដែលគ្មានចែងនៅក្នុងប្រការ ១, ២, និង ៣ ខាងលើ ត្រូវសុំលិខិតអនុញ្ញាតពិសេស ពី សមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់ ។

**នៅពេលឆ្លងកាត់ស្ពាន គ្រប់អ្នកបើកបរយានយន្ត រថយន្តសណ្តោងរ៉ឺម៉ក ឬ សឺមីរ៉ឺម៉ក ត្រូវគោរពតាមទម្ងន់សរុបអនុញ្ញាតអតិបរមា ដែលកំណត់ក្នុងផ្លាកសញ្ញាចរាចរណ៍មានដាក់តាំងនៅពីមុខក្បាលស្ពាន ។

## ទណ្ឌកម្មលើការដឹកជញ្ជូនលើសទម្ងន់

ចំពោះការផ្ទុកលើសទម្ងន់អតិបរមានៃភ្លៅ និង ទម្ងន់សរុបអនុញ្ញាតអតិបរមានៃយានយន្ត នឹងត្រូវទទួលទណ្ឌកម្មស្របតាម **មាត្រា៦០** នៃច្បាប់ស្តីពីផ្លូវថ្នល់ ដូចខាងក្រោម ៖

**១- ការមិនចូលថ្លឹងនៅស្ថានីយជញ្ជីងតាមផ្លូវ ត្រូវ ពិន័យអន្តរការណ៍ជាប្រាក់ ចំនួន ៥00,000 (ប្រាំរយពាន់)រៀល**

**២- មិនលើសពី ៥% ត្រូវ:**

ធ្វើការព្រមានជាលាយ លក្ខណ៍អក្សរ ដោយមិនពិន័យ ។



**៣- លើសពី ៥% នៅ ១0% ត្រូវ:**

ក- ពិន័យជាប្រាក់ចំនួន **១00,000** (មួយរយពាន់)រៀល ក្នុងមួយតោន

ខ- រើទំនិញចេញ និងឃាត់យានជំនិះ ចំនួន ១០(ដប់)ថ្ងៃ

គ- ដកបណ្ណបើកបរព្យួរទុកចំនួន១០(ដប់)ថ្ងៃ

**៤- លើសពី ១0% នៅ ២0% ត្រូវ:**

ក- ពិន័យជាប្រាក់ចំនួន **២00,000** (ពីររយពាន់)រៀល ក្នុងមួយតោន

ខ- រើទំនិញចេញ និងឃាត់យានជំនិះចំនួន ០១(មួយ)ខែ

គ- ដកបណ្ណបើកបរព្យួរទុក ចំនួន ០៦ (ប្រាំមួយ)ខែ ។

**៥- លើសពី ២0% ត្រូវ:**

ក- ពិន័យជាប្រាក់ចំនួន **៣00,000** (បីរយពាន់)រៀល ក្នុងមួយតោន

ខ- រើទំនិញចេញ និងឃាត់យានជំនិះចំនួន ០១(មួយ)ឆ្នាំ

គ- ដកបណ្ណបើកបរព្យួរទុកចំនួន០២(ពីរ)ឆ្នាំ

ក្នុងករណីបទល្មើសលើការផ្ទុកទម្ងន់សរុប ថែមទាំងបទល្មើសលើការផ្ទុកទម្ងន់អតិបរមានៃភ្លៅនោះ ត្រូវធ្វើការផាកពិន័យទាំងពីរករណី ។

** ក្នុងករណីមិនរាងចាល ការពិន័យត្រូវទ្វេរគុណ និង បញ្ឈប់អាជីវកម្មដឹកជញ្ជូនរបស់ក្រុមហ៊ុនចំនួន ០១(មួយ)ឆ្នាំ។